long beach unified school district

DISTRICT Parent Resource Centers

# ចំណុចដ៏ចាំបាច់សំរាប់ទំនាក់ទំនងរវាង សាលារៀន និង ផ្ទះ

## ការចូលរួមចំណែក

ច្បាប់រដ្ឋ និង ច្បាប់សាលារៀនសព្វថ្ងៃនេះ ចាត់ទុកថា ការចូលរួមចំណែកមកពីមាតាបិតា គឺមិនមែនជាការចែងតម្រូវ ឬ មិនមែនជាចំណុចចាំបាច់ក្នុងការជួយសិស្សឲ្យរៀនសូត្របានល្អតលាស់ទៅមុខនោះទេ (Payne, 2006 & Waterman, 2008) ។ ការសិក្សាស្រាវជ្រាវបានផ្ដល់ជាភស្ដុតាងអំពីទំនាក់ទំនងរវាងការចូលរួមចំណែកមកពីមាតាបិតានៅក្នុងកម្មវិធីសិក្សា និង កម្រិតនៃភាពស័ក្តសិទ្ធ ដែលការចូលរួមចំណែកមកពីមាតាបិតានាំមកលើសេចក្ដីជោគជ័យផ្នែករៀនសូត្ររបស់សិស្ស (Lee & Green, 2008) ។ តទៅនេះ គឺជាគោលគំនិតខ្លះៗសំរាប់ប្រើជាមួយ ដើម្បីធ្វើឲ្យការចូលរួមចំណែកមកពីមាតាបិតាមានភាពស័ក្តសិទ្ធទៅលើភាពល្អតលាស់ផ្នែករៀនសូត្ររបស់សិស្ស ...

### សាលាបឋមសិក្សា

- ចូលពិនិត្យនៅតាមបន្ទប់រៀននៃកូនរបស់លោកអ្នក ។ ការធ្វើរបៀបនេះនឹងជួយលោកអ្នកយល់អំពីអ្វី ដែលកូនរបស់លោកអ្នកកំពុងតែរៀននៅក្នុងសាលារៀន និង របៀបនាងរាប់អានជាមួយសិស្សដ៏ទៃ ។
- ចំណាយពេលស្ម័គ្រចិត្តជួយកិច្ចការនៅតាមបន្ទប់រៀន (ឧទាហរណ៍ៈ អានសៀវភៅឲ្យសិស្សស្ដាប់ ឬ ជួយបង្ហាប់សិស្សអំពីរបៀបប្រើ កុំព្យូទ័រ) ។
- គាំទ្រចំពោះកម្មវិធីនៅក្នុងសាលារៀន ដែលសិស្សនឹងចូលរួមចំណែកជាមួយ (ដូចជាៈ កម្មវិធីសម្ដែង ដោយដេរសំលៀកបំពាក់ ឬ ផាត់ពណ៌ជញ្ជាំង ជាដើម) ហើយក៏ឆ្លៀតពេលទៅចូលរួមមើលផង ។
- បើសិនជាសាលារៀននៃកូនរបស់លោកអ្នកមាន បន្ទប់មាតាបិតា ឬ មជ្ឈមណ្ឌល់មាតាបិតា, សូមលោកអ្នកឆ្លៀតឱកាសចូលពិនិត្យ ដើម្បីជួបជាមួយមាតាបិតាដ៏ទៃ និង គ្រូបង្រៀន ឬ ទទួលយកពត៌មានសំខាន់ៗសំរាប់អានសំគាល់ទុក ។
- ចូលរួមស្ដាប់នៅក្នុងកម្មវិធីផ្ដល់ពត៌មាន ដែលសាលារៀនបើកទទួល ដូចជាៈ អំពីអប់រំក្មេង ឬ ការដោះស្រាយបញ្ហាផ្សេងៗ ជាដើម ។
- កាន់ភ្ជាប់នូវកិច្ចសន្យារវាងមាតាបិតា/គ្រូបង្រៀន (គួរចំណាយពេលអានអំពីកិច្ចសន្យានេះឲ្យកូនរបស់លោកអ្នកស្ដាប់ជាមួយ ដើម្បីឲ្យនាងយល់អំពីចំនួនពេលវេលា ដែលត្រូវចំណាយធ្វើ ហូមវើក ជារៀងរាល់ល្ងាច) ។
- សួរទៅកាន់គ្រូបង្រៀននៃកូនរបស់លោកអ្នកមើលថា តើគាត់មានកិច្ចការអ្វីបន្ថែមទេសំរាប់លោកអ្នកអាចប្រើជាមួយបាន ដើម្បីទុកឲ្យកូនរបស់លោកអ្នកធ្វើនៅឯផ្ទះ ។
- ចូលរួមចំណែកជាសមាជិកនៅក្នុងក្រុមប្រឹក្សា ដើម្បីទទួលសិទ្ធិក្នុងការរៀបចំដោះស្រាយបញ្ហានៅក្នុងសាលារៀន (California Parent Center, 2009) ។

### នៅតាមសាលាមធ្យមសិក្សា

- ចូលរួមនៅក្នុងកម្មវិធី ដែលសាលារៀនបើកទទួល (ឧទាហរណ៏ ... Back-to-School Night, Open House, កម្មវិធីប្រជុំ ភីធីអេ/ភីធីអូ, កម្មវិធីផ្ដល់ពត៌មាន ដែលរៀបចំបើកដោយការិយាល័យ ឌីស្រ្ទីគ ឬ កម្មវិធីប្រកួតប្រជែងកីឡានៅតាមសាលារៀន ជាដើម) ។
- ចំណាយពេលស្ម័គ្រចិត្តជួយកិច្ចការនៅតាមសាលារៀន ឬ នៅក្នុងបន្ទប់រៀន ឬ ការិយាល័យសាលារៀន ។
- គាំទ្រចំពោះកម្មវិធីរៃប្រាក់ជួយសាលារៀន ។
- បើសិនជាសាលារៀននៃកូនរបស់លោកអ្នកមាន បន្ទប់មាតាបិតា ឬ មជ្ឈមណ្ឌល់មាតាបិតា, សូមលោកអ្នកឆ្លៀតឱកាសចូលពិនិត្យ ដើម្បីជួបជាមួយមាតាបិតាដ៏ទៃ និង គ្រូបង្រៀន ឬ ទទួលយកពត៌មានសំខាន់ៗសំរាប់អានសំគាល់ទុក ។
- ចូលរួមចំណែកជាសមាជិកនៅក្នុងក្រុមប្រឹក្សា ដើម្បីទទួលសិទ្ធិក្នុងការរៀបចំដោះស្រាយបញ្ហានៅក្នុងសាលារៀន (California Parent Center, 2009) ។

**នៅតាមសាលារៀន “ហាយស្គូល”**

- ចូលរួមនៅក្នុងកម្មវិធី ដែលសាលារៀនបើកទទួល (ឧទាហរណ៏ ... Back-to-School Night, Open House, កម្មវិធីប្រជុំ ភីធីអេ/ភីធីអូ, កម្មវិធីផ្តល់ពត៏មាន ដែលរៀបចំបើកដោយការិយាល័យ ឪស្រ្ទីគ ឬ កម្មវិធីប្រកួតប្រជែងកីឡានៅតាមសាលារៀន ជាដើម) ។
- ចំណាយពេលស្ម័គ្រចិត្តជួយកិច្ចការនៅតាមសាលារៀន ឬ នៅក្នុងបន្ទប់រៀន ឬ ការិយាល័យសាលារៀន ។
- គាំទ្រចំពោះកម្មវិធីរៃប្រាក់ជួយសាលារៀន ។
- បើសិនជាសាលារៀននៃកូនរបស់លោកអ្នកមាន បន្ទប់មាតាបិតា ឬ មជ្ឈមណ្ឌលមាតាបិតា, សូមលោកអ្នកឆ្លៀតឪកាសចូលពិនិត្យ ដើម្បីជួបជាមួយមាតាបិតាដ៏ទៃ និង គ្រូបង្រៀន ឬ ទទួលយកពត៏មានសំខាន់ៗសំរាប់អានសំគាល់ទុក ។
- ជួបជាមួយអ្នកផ្តល់ឪវាទនៃកូនរបស់លោកអ្នក ដើម្បីពិគ្រោះអំពីមធ្យោបាយរៀនបន្តដល់កម្រិតកាន់តែខ្ពង់ខ្ពស់ទៅថ្ងៃមុខ
- ចូលរួមចំណែកជាសមាជិកនៅក្នុងក្រុមប្រឹក្សា ដើម្បីទទួលសិទ្ធិក្នុងការរៀបចំដោះស្រាយបញ្ហានៅក្នុងសាលារៀន (California Parent Center, 2009) ។

សូមលោកអ្នកជួយបង្ហាញបន្ថែមអំពីរបៀបបង្កើន ទំនាក់ទំនងយ៉ាងប៉ិនប្រសប់រវាងផ្ទះ/សាលារៀន ដោយប្រើ អ៊ីម៉ែល ទៅកាន់ svelasco@lbschools.net ឬ ចូលពិនិត្យជួបជាមួយនាងខ្ញុំ និង បុគ្គលិកផ្សេងៗផ្ទាល់តែម្តងនៅក្នុង មជ្ឈមណ្ឌលមាតាបិតាប្រចាំ ឪស្រ្ទីគ ទាំង បី កន្លែង ។


Sandra J. Velasco

អ្នកសម្របសម្រួលកម្មវិធី – មជ្ឈមណ្ឌលមាតាបិតាប្រចាំ ឪស្រ្ទីគ

ខែវិច្ឆិកា – ខែធ្នូ ឆ្នាំ2009


ដកស្រង់ចេញពីៈ

California Parent Center, 2009